**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦៧៨ រចណ.ចព-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការ ក្រុងភ្នំពេញ**

**លោកព្រះរាជអាជ្ញាអមតុលាការ ក្រុងភ្នំពេញ**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការអនុវត្តន៍សាលក្រម ឬ សាលដីកាស្ថាពរ ព្រមទាំងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ និងអយ្យការ

**យោង:** -លិខិតបង្គាប់លេខ ១១៧ សរ.រវ-៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ ។

-លិខិតលេខ ១១៨ រប.៩២១-៩៩ ចុះថ្ងៃទី២៩-០៣-៩៩ របស់តុលាការក្រុងភ្នំពេញ

-លិខិតលេខ ៦៥ ព្រទ៩៤០១-៩៩ ចុះថ្ងៃទី០២-០៤-៩៩ របស់អយ្យការក្រុងភ្នំពេញ

-ស្មារតីអង្គប្រជុំរបស់ក្រសួងយុត្តិធម៌ នៅថ្ងៃទី២១-០៤-៩៩ និងថ្ងៃទី១៧-០៥-៩៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកថា ការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗ របស់តុលាការ និងអយ្យការ ត្រូវតែអនុវត្តជាធម្មតាដោយពុំអាចផ្អាកជាបណ្តោះអាសន្នបានទេ ហើយអស់លោកត្រូវតែគោរពតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី និងសេចក្តីបង្គាប់លេខ ១១៧ សរ.រវ-៩៧ ចុះថ្ងៃទី៣១-០១-៩៧ ដោយក្នុងការអនុវត្តនោះលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា ត្រូវតែសហការគ្នាអនុវត្តអោយបានល្អប្រសើរនៅក្នុងអង្គការតុលាការ ។ ដូច្នេះអំណើះតទៅសាលក្រម ឬសាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ និងអយ្យការ អស់លោកត្រូវតែចាត់អនុវត្តតាមលិខិតណែនាំនេះអោយមានប្រសិទ្ធិភាពខ្ពស់បំផុត ។

សូមអស់លោក ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

ចម្លងជូន

-លោកប្រធានតុលាការខេត្ត-ក្រុង

-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង

-ដើម្បីជ្រាប និង អនុវត្ត